GC LiFE

# GC ការពារនារី



## តើអ្វីទៅជា GC គាំពារនារី?

GC គាំពារនារី គឺជាគម្រោងធានារ៉ាប់រងដែលមានរយៈពេលចាប់ពី10 ទៅ 25 ឆ្នាំ ដោយរចនាឡើងយ៉ាងពិសេសសម្រាប់នារីគ្រប់រូបដែលកំពុងរៀបចំផែនការដើម្បីសម្រេចនូវគោលដៅហិរញ្ញវត្ថុរបស់ខ្លួន។

## តើអ្នកណាអាចទទួលបានការធានាពីគម្រោងមួយនេះ?

នារីដែលមានអាយុចាប់ពី 18 ឆ្នាំ ដល់ 55 ឆ្នាំ។

## ហេតុអ្វីបានជាចាំបាច់ជ្រើសរើស GC គាំពារនារី?

GC គាំពារនារី គឺជាគម្រោងធានារ៉ាប់រងដែលរចនាឡើងយ៉ាងពិសេសសម្រាប់នារី ដោយផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដើម្បីសម្រាលបន្ទុកហិរញ្ញវត្ថុដែលបណ្តាលមកពីការបាត់បង់ប្រាក់ចំណូល ឬគ្រោះថ្នាក់អកុសលណាមួយ។ បន្ថែមពីលើការការពារមរណភាព និងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ គម្រោងនេះផ្តល់នូវការការពារលើជំងឺធ្ងន់ធ្ងរកម្រិតដំបូង និងកម្រិតធ្ងន់សម្រាប់ស្ត្រី។

ជាពិសេសបំផុតនោះគឺគម្រោង GC គាំពារនារី ផ្តល់នូវអត្ថប្រយោជន៍បង្កក់ខែកូន អត្ថប្រយោជន៍ខួប៥ឆ្នាំនៃបណ្ណសន្យារ៉ាប់រង អត្ថប្រយោជន៍ថែទាំសុខភាព និងអត្ថប្រយោជន៍ដល់កាលកំណត់ ជាមួយនឹងទឹកប្រាក់សរុបរហូតដល់ 75%នៃទឹកប្រាក់ត្រូវបានធានា។

## កម្មវត្ថុនៃការធានារ៉ាប់រង

អាយុជីវិតនៃអ្នកត្រូវបានធានារ៉ាប់រង។



## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុចាប់ផ្តើមធានា | 18 ឆ្នាំ - 55 ឆ្នាំ |
| រយៈពេលធានារ៉ាប់រង/<br>រយៈពេលបង់បុព្វលាភ | 10 ឆ្នាំ - 25 ឆ្នាំ |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $10,000 ឡើង |

## លក្ខខណ្ឌនៃការបង់បុព្វលាភ

| | |
|---|---|
| វិធីសាស្រ្តបង់បុព្វលាភ | ប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស |
| មធ្យោបាយបង់បុព្វលាភ | ការផ្ទេរប្រាក់តាម App ឬគណនីធនាគារ<br>សាច់ប្រាក់ មូលប្បទានបត្រ |
| ការបំពាន | បន្ទាប់ពីការបង់បុព្វលាភធានារ៉ាប់រងលើកទី ១ (មួយ) ការខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រងបន្តបន្ទាប់នៅកាលបរិច្ឆេទដល់កាលកំណត់បង់នឹងត្រូវបានចាត់ទុកជាការបំពានលក្ខខណ្ឌបង់បុព្វលាភធានារ៉ាប់រង។ ប្រសិនបើបុព្វលាភធានារ៉ាប់រងនៅតែមិនទាន់បានបង់បន្ទាប់ពីរយៈពេលអនុគ្រោះ (30ថ្ងៃ) ដល់កាលកំណត់ បណ្ណសន្យារ៉ាប់រងនឹងត្រូវផ្អាកសុពលភាព គិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃផុតកំណត់នៃរយៈពេលអនុគ្រោះ ហើយបណ្ណសន្យារ៉ាប់រងនេះនឹងមិនមានសុពលភាពក្នុងអំឡុងពេលនៃការផ្អាកសុពលភាពនេះឡើយ។ |

## វិសាលភាពនៃការធានារ៉ាប់រង

ផលិតផលនេះផ្តល់នូវ៖

១. ការការពារលើមរណភាព និងពិការភាពក្នុងកំឡុងពេលដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព។

២. អត្ថប្រយោជន៍រស់រានមានជីវិត និងអត្ថប្រយោជន៍បង្គក់ខែកូន ដែលនឹងត្រូវផ្តល់ជូនតាមកាលបរិច្ឆេទ និងលក្ខខណ្ឌដែលបានកំណត់។

៣. ការការពារលើជំងឺធ្ងន់ធ្ងរកម្រិតដំបូង និងកម្រិតធ្ងន់សម្រាប់ស្ត្រី។

## អត្ថប្រយោជន៍ធានារ៉ាប់រង

| | |
|---|---|
| អត្ថប្រយោជន៍បង្គក់ខែកូន និង<br>អត្ថប្រយោជន៍រស់រានមានជីវិត | % នៃទឹកប្រាក់ត្រូវបានធានាដូចបង្ហាញក្នុងតារាងខាងក្រោម |
| សំណងមរណភាព | 100% នៃទឹកប្រាក់ត្រូវបានធានានឹងត្រូវផ្តល់ជូន ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព* |
| សំណងពិការភាពទាំងស្រុង<br>និងជាអចិន្ត្រៃយ៍ | 100% នៃទឹកប្រាក់ត្រូវបានធានានឹងត្រូវផ្តល់ជូន ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលរងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍* |
| អត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរ<br>កម្រិតដំបូងសម្រាប់ស្ត្រី** | 25%នៃទឹកប្រាក់ត្រូវបានធានានឹងត្រូវផ្តល់ជូន ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងធ្វើរោគវិនិច្ឆ័យឃើញថាមានអាការៈជំងឺធ្ងន់ធ្ងរកម្រិតដំបូង |
| អត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរ<br>កម្រិតធ្ងន់សម្រាប់ស្ត្រី** | 100%នៃទឹកប្រាក់ត្រូវបានធានានឹងត្រូវផ្តល់ជូន ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងធ្វើរោគវិនិច្ឆ័យឃើញថាមានអាការៈជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់* |

| ឆ្នាំនៃបណ្ណសន្យារ៉ាប់រង | អត្ថប្រយោជន៍បង្កក់ខែកូន** *** | %នៃទឹកប្រាក់ត្រូវបានធានា |
|---|---|---|
| 2 - 5 | ការសម្រាលកូនចំនួនពីរលើក | 2% សម្រាប់ការសម្រាលក្នុងមួយលើក |

| ខួបនៃបណ្ណសន្យារ៉ាប់រង | អត្ថប្រយោជន៍រស់រានមានជីវិត | %នៃទឹកប្រាក់ត្រូវបានធានា |
|---|---|---|
| 5 | អត្ថប្រយោជន៍ខួប៥ឆ្នាំ នៃបណ្ណសន្យារ៉ាប់រង | 10% ដោយត្រូវដកចេញនូវចំនួន អត្ថប្រយោជន៍បង្កក់ខែកូនសរុបដែល បានទូទាត់រួច (ប្រសិនបើមាន) |
| 6 | អត្ថប្រយោជន៍ថៃទាំសុខភាព | 1% |
| 8 | | 1% |
| 10 | | 1% |
| 12 | | 1% |
| 14 | | 1% |
| 16 | | 2% |
| 18 | | 2% |
| 20 | | 2% |
| 22 | | 2% |
| 24 | | 2% |
| ដល់កាលកំណត់ | អត្ថប្រយោជន៍ដល់កាលកំណត់ | 50% |

*ដកចេញនូវអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរកម្រិតដំបូងសម្រាប់ស្ត្រីដែលបានផ្តល់សំណងរួច
**រយៈពេលរង់ចាំត្រូវបានអនុវត្ត!  ***រយៈពេលរស់រានមានជីវិតត្រូវបានអនុវត្ត!

## ទទួលបានការការពារកាន់តែប្រសើរដោយ បន្ថែមនូវអត្ថប្រយោជន៍ខាងក្រោម៖

- អត្ថប្រយោជន៍ការពារបន្ថែមលើគ្រោះថ្នាក់ដោយចៃដន្យ
- អត្ថប្រយោជន៍លើការព្យាបាលជំងឺធ្ងន់ធ្ងរ
- អត្ថប្រយោជន៍បន្ថែមការការពារ
- អត្ថប្រយោជន៍លើកលែងបុព្វលាភធានារ៉ាប់រង



# ការបង្ហាញអំពី អត្ថប្រយោជន៍ធានារ៉ាប់រង

ឧទាហរណ៍៖ អ្នកស្រី ពិសី មានអាយុ 25ឆ្នាំ។ គាត់បានជាវនូវផលិតផល GC គាំពារនារី ដែលមានទឹកប្រាក់ត្រូវបានធានាចំនួន $20,000 រយៈពេលធានារ៉ាប់រង 20ឆ្នាំ និងរយៈពេលបង់បុព្វលាភ 20ឆ្នាំ។ បន្ថែមពីលើនេះ អ្នកស្រីក៏បានបន្ថែមនូវអត្ថប្រយោជន៍លើកលែងបុព្វលាភធានារ៉ាប់រង (ជម្រើសទី១) អត្ថប្រយោជន៍លើការព្យាបាលជំងឺធ្ងន់ធ្ងរ ដែលមានទឹកប្រាក់ត្រូវបានធានា $20,000 និងអត្ថប្រយោជន៍ការពារបន្ថែមលើគ្រោះថ្នាក់ជាយថាហេតុ ដែលមានទឹកប្រាក់ត្រូវបានធានាចំនួន $100,000។ បុព្វលាភប្រចាំឆ្នាំសរុបដែលត្រូវបង់គឺ $895.90 ផលិតផល GC គាំពារនារី = $682.40 + អត្ថប្រយោជន៍លើការព្យាបាលជំងឺធ្ងន់ធ្ងរ = $51.20 + អត្ថប្រយោជន៍ការពារបន្ថែមលើគ្រោះថ្នាក់ជាយថាហេតុ = $150 + អត្ថប្រយោជន៍លើកលែងបុព្វលាភធានារ៉ាប់រង = $12.30)

សេណារីយ៉ូទី១: អ្នកស្រី ពិសី បានសម្រាលកូនប្រុសម្នាក់នៅអាយុ 26 ឆ្នាំ និងកូនស្រីម្នាក់នៅអាយុ 28 ឆ្នាំ។ អ្នកស្រីនៅរស់រានរហូតដល់បណ្ណសន្យារ៉ាប់រងដល់កាលកំណត់។




សេណារីយ៉ូទី២: អ្នកស្រី ពិសីបានសម្រាលកូនប្រុសម្នាក់នៅអាយុ 26 ឆ្នាំ។ ជាអកុសល នៅពេលអ្នកស្រីអាយុ 29 ឆ្នាំ អ្នកស្រីបានធ្វើរោគវិនិច្ឆ័យរកឃើញជំងឺមហារីកសុដន់កម្រិតដំបូង ហើយក្រោយមកនៅពេលដែលអ្នកស្រីអាយុ 30 ឆ្នាំ អ្នកស្រីបានកើតជំងឺធ្ងន់ធ្ងរមួយដែលតម្រូវឲ្យអ្នកស្រីធ្វើការវះកាត់ផ្សាំលំពែង (ការវះកាត់ផ្សាំលំពែងរបស់អ្នកស្រីបានប្រព្រឹត្តិទៅដោយជោគជ័យ)។ ជាអកុសលម្តងទៀត នៅពេលអ្នកស្រីអាយុ 40 ឆ្នាំ ជំងឺមហារីកសុដន់របស់អ្នកស្រីបានវិវត្តទៅកម្រិតធ្ងន់។ អ្នកស្រីបានទទួលមរណភាពដោយសារតែជំងឺនេះនៅអាយុ 41 ឆ្នាំ។




សេណារីយ៉ូទី៣: អ្នកស្រី ពិសីបានសម្រាលកូនប្រុសម្នាក់នៅអាយុ 26 ឆ្នាំ និងកូនស្រីម្នាក់នៅអាយុ 28 ឆ្នាំ។ ជាអកុសល ក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ នៅពេលដែលអ្នកស្រីពិសីអាយុ 40 ឆ្នាំ អ្នកស្រីបានទទួលមរណភាពដោយសារគ្រោះថ្នាក់ចរាចរណ៍ ក្នុងអំឡុងពេលជិះរថយន្តក្រុងធ្វើដំណើរទៅផ្ទះ។





## ករណីមិនធានាសំខាន់ៗ

### ១. មរណភាព

មិនមានសំណងមរណភាពនឹងត្រូវផ្តល់ជូននោះទេ ប្រសិនបើមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រង ត្រូវបានបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖

១ ការធ្វើអត្តឃាតក្នុងរយៈពេល ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយ។
២ ការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។
៣ វីរុសហ៊ីវ (HIV) និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ (HIV) ដែលរួមមានទាំងជំងឺអេដស៍ និង/ឬការបំលែង ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍។
៤ ការប្រើប្រាស់ថ្នាំញៀន ឬថ្នាំភ្លេចអារម្មណ៍ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬរោគសញ្ញាផ្សេងៗដូចដែលបានកំណត់ដោយច្បាប់ដែលបានចូលជាធរមាន។

### ២. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

ក្រុមហ៊ុនមិនធានាលើការបាត់បង់ ឬពិការភាពដែលបណ្តាលមកពីព្រឹត្តិការណ៍ដែលកើតឡើង ដោយផ្ទាល់ ឬដោយប្រយោលទាំងស្រុង ឬដោយផ្នែកដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖

១ ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។
២ ការឆ្លងវីរុសហ៊ីវ រោគសញ្ញានៃជំងឺអេដស៍ ឬជំងឺដែលទាក់ទងនឹងជំងឺអេដស៍។
៣ សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) ការឈ្លានពាន សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ចលាចលស៊ីវិល ការធ្វើកុបកម្ម ការធ្វើកូដកម្ម ការបះបោរប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។

៤ ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងប្រព្រឹត្តបទឧក្រិដ្ឋ ឬខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងកំពុងត្រូវបានតាមចាប់ខ្លួន ឬត្រូវរងការចាប់ខ្លួន ឬកំពុងរត់គេចពីការចាប់ខ្លួន។

៥ ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការបញ្ជា ការធ្វើប្រតិបត្តិការជួសជុលថែទាំ ឬត្រូវបានដឹកជញ្ជូនដោយ យានឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាសនានា លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើប្រតិបត្តិការជាទៀងទាត់តាមកាលវិភាគ និងតាមគន្លងផ្លូវដឹកជញ្ជូនអ្នកដំណើរផ្លូវអាកាសដែលបានកំណត់ជាមុនរបស់ក្រុមហ៊ុន។

៦ ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងបំពេញកាតព្វកិច្ចជាយោធា ប៉ូលីស ឬជាអ្នកស្ម័គ្រចិត្ត ចូលរួមក្នុងសង្គ្រាម ឬការបង្ក្រាបឧក្រិដ្ឋកម្ម។

៧ ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម៖

ក) អ្នកត្រូវបានធានារ៉ាប់រងបានទទួល ឬកំពុងទទួលការព្យាបាល

ខ) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ

គ) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ

ឃ) វត្តមាននៃស្ថានភាពនោះអាចត្រូវបានកត់សម្គាល់ដោយបុគ្គលទូទៅក្នុងកាលៈទេសៈ ណាមួយ។

៨ អ្នកត្រូវបានធានារ៉ាប់រងធានាស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយលើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

៩ ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

## ៣. ជំងឺធ្ងន់ធ្ងរសម្រាប់ស្ត្រី

ក្រុមហ៊ុនមិនផ្តល់សំណងចំពោះជំងឺធ្ងន់ធ្ងរសម្រាប់ស្ត្រីទាំងឡាយណាដែលកើតឡើងដោយផ្ទាល់ ឬ ដោយប្រយោលមកពីព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖

១ ជំងឺផ្សេងទៀតក្រៅពីរោគវិនិច្ឆ័យជំងឺធ្ងន់ធ្ងរ ដូចមានកំណត់នៅក្នុងកិច្ចសន្យា។

២ ជំងឺអេដស៍ ឬជំងឺបណ្តាលមកពីជំងឺអេដស៍ ឬជំងឺពាក់ព័ន្ធនឹងវីរុសហ៊ីវ។

៣ ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុននិងទទួលយកដោយក្រុមហ៊ុន។អ្នកត្រូវបានធានារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម៖

ក) អ្នកដែលត្រូវបានធានាបានទទួល ឬកំពុងទទួលការព្យាបាល

ខ) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ

គ) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ

ឃ) វត្តមាននៃស្ថានភាពនោះអាចត្រូវបានកត់សម្គាល់ដោយបុគ្គលទូទៅក្នុងកាលៈទេសៈ ណាមួយ។

៤ អ្នកត្រូវបានធានារ៉ាប់រងធានាស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយលើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

៥ ជំងឺធ្ងន់ធ្ងរទាំងអស់ដែលកើតមាន ឬធ្វើរោគវិនិច្ឆ័យរកឃើញក្នុងរយៈពេលរង់ចាំដោយរាប់បញ្ចូលទាំងជំងឺធ្ងន់ធ្ងរកម្រិតដំបូងដែលត្រូវបានរកឃើញពេលធ្វើរោគវិនិច្ឆ័យដំបូងក្នុងរយៈពេលរង់ចាំហើយវិវត្តទៅជាជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់បន្ទាប់ពីរយៈពេលរង់ចាំត្រូវបានផុតកំណត់។

៦ ជំងឺកើតចេញពីការសាយភាយដោយផ្ទាល់ ឬដោយប្រយោលនូវធាតុវិទ្យុសកម្មពីថាមពលនុយក្លេអ៊ែរ ឬសំណល់នុយក្លេអ៊ែរ ដែលបង្កឡើងដោយដំណើរការបំលែងថាមពលនុយក្លេអ៊ែរ ឬអាវុធនុយក្លេអ៊ែរ។

# ចំណាំ៖

ខ្លឹមសារក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នា
ដោយសង្ខេប។
សម្រាប់ព័ត៌មានលម្អិតនៃការធានារ៉ាប់រង
រួមមានអត្ថប្រយោជន៍ធានារ៉ាប់រង ករណីមិនធានា
និងលក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា
សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។

ទំនាក់ទំនងមកកាន់យើងខ្ញុំ


023-989-218 / 098-989-218

service@gc-life.com.kh www.gc-life.com.kh

វ៉នផាក ផ្ទះលេខ A១២ ផ្លូវR៨
ភូមិ ១ សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ